**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 08PR-25/EoJ

14 February 2025

## Japan Provides US$204,720 for Installment of a Machine for Orthopedic Component Factory, and Construction of a New Pier in Koh Rong Commune

The Government of Japan will provide US$204,720 in total for two recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of two recipients respectively, to carry out the following projects.

1. 'The Project for the Installment of Component Manufacturing Machine at Orthopedic Component Factory in Phnom Penh' (US$63,470)
Recipient: Orthopedic Component Factory

This grant will be used to install a new component manufacturing machine at the Orthopedic Component Factory to replace an old manufacturing machine that had limited functionality. The Orthopedic Component Factory required more time to produce orthopedic component. It is expected that the new machine will contribute to improved productivity and quality at the Orthopedic Component Factory.

2. 'The Project for the Construction of Pier in Koh Rong Commune, Koh Rong District, Preah Sihanouk Province' (US$141,250)
Recipient: Koh Rong District Administration

This grant will be used to construct a new pier in Koh Rong Commune in Sihanouk Province for transportation between Koh Rong island and the mainland. The new pier will provide approximately 3,000 local residents with a safe and efficient means of transportation. In addition, this pier will help to facilitate the transportation of goods and will support the security activities of the maritime police in emergency situations.

Japan's *"KUSANONE" Projects* started in Cambodia in 1991 in order to support Cambodia's

reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$70 million for mainly local authorities and non-governmental organizations to implement 694 *KUSANONE* projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

ស្ថានទូតជប៉ុន
ប្រចាំព្រះរាជាណាចក្រកម្ពុជា
សេចក្តីប្រកាសពត៌មាន

លេខ. 08PR-25/EoJ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥

**ជប៉ុនផ្តល់ថវិកា ២០៤,៧២០ ដុល្លារអាមេរិក**
**សម្រាប់ការតម្លើងម៉ាស៊ីននៅរោងចក្រផលិតឧបករណ៍សិប្បនិម្មិត**
**និងការសាងសង់សាងសង់កំពង់ផែក្នុងសង្កាត់កោះរ៉ុង**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន ២០៤,៧២០ ដុល្លារអាមេរិក ដល់ស្ថាប័នទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយទាំងពីរ ដើម្បីអនុវត្តគម្រោងដូចតទៅ៖

**១. គម្រោងតម្លើងម៉ាស៊ីនផលិតឧបករណ៍ នៅរោងចក្រផលិតឧបករណ៍សិប្បនិម្មិត ក្នុងក្រុងភ្នំពេញ (ថវិកាចំនួន ៦៣,៤៧០ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ រោងចក្រផលិតឧបករណ៍សិប្បនិម្មិត

ជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីតម្លើងម៉ាស៊ីនផលិតឧបករណ៍ថ្មីមួយ នៅរោងចក្រផលិតឧបករណ៍សិប្បនិម្មិត ជំនួសដោយម៉ាស៊ីនផលិតចាស់ដែលមុខងារនៅមានកម្រិត។ រោងចក្រផលិតឧបករណ៍សិប្បនិម្មិត ត្រូវចំណាយពេលវេលាច្រើនដើម្បីផលិតឧបករណ៍សិប្បនិម្មិត។ យើងរំពឹងថាម៉ាស៊ីនថ្មីនេះនឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងគុណភាពនៅក្នុងរោងចក្រផលិតឧបករណ៍សិប្បនិម្មិត។

**២. គម្រោងសាងសង់កំពង់ផែ ក្នុងសង្កាត់កោះរ៉ុង ក្រុងកោះរ៉ុង ខេត្តព្រះសីហនុ (ថវិកាចំនួន ១៤១,២៥០ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ រដ្ឋបាលក្រុងកោះរ៉ុង

ជំនួយនេះ នឹងត្រូវបានប្រើប្រាស់ដើម្បីសាងសង់កំពង់ផែថ្មីមួយ ក្នុងសង្កាត់កោះរ៉ុង ខេត្តព្រះសីហនុ សម្រាប់ការដឹកជញ្ជូនរវាងកោះរ៉ុង និងដីគោក។ កំពង់ផែថ្មីនេះនឹងផ្តល់ឱ្យប្រជាជនមូលដ្ឋានប្រមាណ ៣,០០០នាក់ ជាមួយនឹងការធ្វើដំណើរប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។ លើសពីនេះទៅទៀត ផែនេះនឹងជួយសម្រួលដល់ការដឹកជញ្ជូនទំនិញ ក៏ដូចជានឹងគាំទ្រសកម្មភាពសន្តិសុខរបស់កងទ័ពជើងទឹកក្នុងស្ថានភាពអាសន្ននានា។

ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៧០លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោង គូសាណូណិ ចំនួន ៦៩៤ គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង**
**សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**ថ្ងៃ១៤ ខែកុម្ភៈ ឆ្នាំ២០២៥**

សូមគោរព

- **ឯកឧត្តម ខុម ផលលឿន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជានាយកនៃមូលនិធិជនពិការ
- **លោក ហឿង សុផាន់ណា** ប្រធានរោងចក្រផលិតឧបករណ៍សិប្បនិម្មិត
- **លោក នួន ប៊ុនថុល** អភិបាលក្រុងកោះរ៉ុង
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

សួស្តីអ្នកទាំងអស់គ្នា។ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាដែលនឹងត្រូវបានអនុវត្តក្រោមជំនួយឥតសំណងគូសាណូណិសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ នាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាននិងកំពុងអនុវត្តជំនួយឥតសំណងគូសាណូណិនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណូណិ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន ហើយនៅក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុន បានអនុវត្តជិត ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណូណិ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះបានចូលរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណភាពនៃជីវភាពរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ពេលនេះ ខ្ញុំសូមណែនាំគម្រោង ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ។

សម្រាប់គម្រោងទី១ ដែលអនុវត្តដោយរោងចក្រផលិតឧបករណ៍សិប្បនិម្មិត រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ៦៣,៤៧០ ដុល្លារអាមេរិក (ហុកសិបបីពាន់បួនរយចិតសិបដុល្លារអាមេរិក) ដើម្បីតម្លើងម៉ាស៊ីនផលិតឧបករណ៍ថ្មីមួយ ជំនួសឲ្យម៉ាស៊ីនផលិតចាស់ដែលមុខងារមានកម្រិត។ យើងរំពឹងថាម៉ាស៊ីនថ្មីនេះនឹងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវផលិតភាព និងគុណភាពក៏ដូចជា ចំណាយពេលវេលាតិចជាងមុនដើម្បីផលិតឧបករណ៍សិប្បនិម្មិតនៅក្នុងរោងចក្រផលិតឧបករណ៍សិប្បនិម្មិត ។

សម្រាប់គម្រោងទី២ ដែលអនុវត្តដោយរដ្ឋបាលក្រុងកោះរ៉ុង រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១៤១,២៥០ ដុល្លារអាមេរិក (មួយរយសែសិបមួយពាន់ពីររយហាសិបដុល្លារអាមេរិក) ដើម្បីសាងសង់កំពង់ផែថ្មីមួយ ក្នុងសង្កាត់កោះរ៉ុង ដែលនឹងជួយសម្រួលការដឹកជញ្ជូនរវាងកោះរ៉ុង និងដីគោក។ កំពង់ផែថ្មីនេះនឹងផ្តល់ឱ្យប្រជាជនមូលដ្ឋានប្រមាណ ៣,០០០នាក់ ជាមួយនឹងការធ្វើដំណើរប្រកបដោយ

សុវត្ថិភាព និងប្រសិទ្ធភាព។ លើសពីនេះទៅទៀត ផែនេះនឹងជួយសម្រួលដល់ការដឹកជញ្ជូនទំនិញ ក៏ដូចជានឹងគាំទ្រសកម្មភាពរបស់កងទ័ពជើងទឹកក្នុងស្ថានភាពអាសន្ននានា។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានសង្កេតឃើញការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជានាពេលថ្មីៗនេះ។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមជាច្រើន ដែលជប៉ុនអាចជួយបាន ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។ ដូច្នេះ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការផ្សេងៗ រួមទាំង "គូសាណូណិ" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ ឯកឧត្តម លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណសម្រាប់ការយកចិត្តទុកដាក់ស្តាប់។